ព្រះគម្ពីរសំរាប់កុមារ
សូមបង្ហាញជូន

# ព្រះជាម្ចាស់
# លើកកិត្តិយ
# លោកយ៉ូសែ
# បដែលជា
# ទាសករ



និពន្ធដោយ៖ Edward Hughes

ធ្វើការពន្យល់ដោយ៖ M. Maillot; Lazarus
Alastair Paterson

កែសម្រួលដោយ៖ M. Maillot; Sarah S.

បកប្រែដោយ៖ www.christian-translation.com

ផលិតដោយ៖ Bible for Children
www.M1914.org

©2023 Bible for Children, Inc.
អាជ្ញាប័ណ្ណ៖ លោកអ្នកមានសិទ្ធិក្នុងការថតចម្លង ឬបោះពុម្ពរឿងនេះបាន
តែលោកអ្នកមិនអាចយកវាទៅលក់បានទេ។

លោកយ៉ូសែប ត្រូវបានលោកបូទីផាដែលជាចៅហ្វាយចាស់របស់លោក
បានយកលោកមកឃុំក្នុងពន្ធនាគារដោយឥតកំហុស។ នៅក្នុង
ពន្ធនាគារ លោកយ៉ូសែប បានស្តាប់បង្គាប់
និង ជួយការងារជាច្រើនផង។
លោកនាយកពន្ធនាគា
ទុកចិត្តលោកយ៉ូសែប
ហើយប្រគល់ឲ្យលោកគ្រប់
គ្រងអ្នកទោសទាំងអស់
ដែលជាប់ឃុំ។
ដោយសារព្រះជាម្ចាស់
គង់ជាមួយលោកយ៉ូសែប
ពន្ធនាគារ បានត្រលប់
ជាកន្លែងដ៏ល្អមួយ
សម្រាប់មនុស្សគ្រប់គ្នា។



មហាតលិកដែលមាននាទីថ្វាយនំបុ័ង្គ
និង មហាតលិកម្នាក់ទៀតដែលមាន
នាទីថ្វាយស្រាបានប្រព្រឹត្តខុស ក៏បាន
ជាប់ឃុំនៅទីនោះដែរ។ លោកយ៉ូសែប
សួរលោកទាំងពីរថា ៖



“ហេតុអ្វីបានជាថ្ងៃនេះ លោកមានទឹកមុខក្រៀមក្រំម្លេះ?”។ អ្នកដែល មានទឹកមុខក្រៀមក្រំនោះបានឆ្លើយថា ៖ “យើងខ្ញុំបានយល់ចម្លែកណាស់ ហើយគ្មាននរណាម្នាក់អាចកាត់ស្រាយន័យការយល់សប្តិរបស់យើងខ្ញុំផង”។



លោកយ៉ូសែប ឆ្លើយតបថា ៖ “ព្រះជាម្ចាស់អាចធ្វើបាន! សូមលោកនិយាយប្រាប់ខ្ញុំអំពីការយល់សប្តិនោះមើល”។



លោកយ៉ូសែបមានប្រសាសន៍ទៅគាត់ថា៖ “សុបិន្តរបស់លោកមាន
ន័យដូចតទៅនេះ: បីថ្ងៃទៀត ព្រះចៅផារ៉ោននឹងលើកកិត្តិយសលោក
ឡើង ហើយតែងតាំងលោក ឲ្យបំពេញមុខងាររបស់លោកឡើងវិញ។



សូមលោកមេត្តាកុំភ្លេចខ្ញុំ ដែលធ្លាប់នៅជាមួយលោក សូមមេត្តាទូល
ព្រះចៅផារ៉ោនឲ្យបានជ្រាបពីរឿងខ្ញុំ ហើយយកខ្ញុំចេញពីពន្ធនាគារនេះ
ផង”។ រីឯសុបិន្ត របស់មហាតលិក ដែលមាននាទីថ្វាយនំប៉័ង្គ គឺជា
ដំណឹងដ៏សែនអាក្រក់។ លោកយ៉ូសែប មានប្រសាសន៍គាត់ថា ៖
“នៅបីថ្ងៃទៀត
លោកនឹងត្រូវស្លាប់”។
សុបិន្តនោះបាន
ក្លាយជាការពិត។



ប៉ុន្តែ មហាតលិកដែលមាននាទីថ្វាយស្រានោះ
ភ្លេចលោកយ៉ូសែបឲ្យឈឹងស្ងួន្យ គឺរហូតទាល់តែមាន
ថ្ងៃមួយនោះ ព្រះចៅផារ៉ោនតើនឡើងទាំងមានព្រះ
ទ័យព្រួយ។ ព្រះអង្គមានព្រះបន្ទូលថា ៖
“យើងបានសុបិន្តនិមិត្តមួយ
ហើយគ្មានអ្នកប្រាជ្ញ
ឬអ្នកណាម្នាក់
អាចបកស្រាយ
ន័យសុបិន្តនោះ
ឲ្យយើងបានសោះ”។ ស្រាប់តែ
មហាតលិកដែលមាននាទីថ្វាយស្រា
នោះ បាននឹក ឃើញលោកយ៉ូសែប
ដែលជាប់ឃុំក្នុងពន្ធនាគារ។
លោកក៏ទូលព្រះ
ចៅផារ៉ោនអំពីលោកយ៉ូសែប។





ព្រះចៅផារ៉ោនបានចេញបញ្ជាឲ្យលោកយ៉ូសែប
ចូលគាល់ទ្រង់ជាបន្ទាន់។ លោកយ៉ូសែបទូលព្រះរាជាថា
៖ សុបិន្តនិមិត្តរបស់ព្រះអង្គ គឺជាព្រះរាជសារពីព្រះជាអម្ចាស់។
ក្នុងរវាងប្រាំពីរឆ្នាំស្រុកអេស៊ីនឹងមានភោគផលជាបរិបូ ហើយប្រាំពីរឆ្នាំ
ក្រោយមកទៀតនឹងមានកើតគ្រោះទុរ្ភិក្សយ៉ាងអាក្រក់ដល់ស្រុកអេស៊ីប។



លោកយ៉ូសែបទូលព្រះចៅផារ៉ោនថា ៖
“ឥឡូវនេះ សូមព្រះករុណារករៀបចំ
ផែនការរក្សាស្បៀងអាហារទុកក្នុងរយៈ
ពេលប្រាំពីរឆ្នាំដែលសំបូរស្បៀងអាហារនោះ
ដើម្បី កុំអោយប្រជាជនត្រូវ
ស្លាប់ដោយអត់ឃ្លាន”។



ពេលនោះព្រះចៅផារ៉ោន
បានប្រកាសថា ៖ “ព្រះជាអម្ចាស់គង់
ជាមួយលោក! ដូច្នេះហើយសុំតែងតាំង
លោកឲ្យគ្រប់គ្រងលើស្រុកអេស៊ីបទាំងមូល
ក្នុងចំ ណោមអ្នកដែល
មានអំណាចទាំង
អស់ក្នុងស្រុកអេស៊ីប
លោកជាមនុស្សដែល
មានអំណាចទីពីរ
បន្ទាប់ពីយើង”។



ប្រាំពីរឆ្នាំដ៏សំបូរសប្បាយក៏បានចូលមកដល់។ បន្ទាប់មកទៀត គឺ
ប្រាំពីរឆ្នាំនៃគ្រោះទុរ្ភិក្សក៏បានមកដល់។ គ្រប់ទីកន្លែង នានាមានការខ្វះ
ម្ហូបអាហារទទួលទាន ប៉ុន្តែនៅស្រុកអេស៊ីបវិញ គឺមានស្បៀងអាហារ
ទុកយ៉ាងបរិបូរ។ គ្រោះទុរ្ភិក្សនោះ ក៏ បានប៉ះពាល់ដល់គ្រួសាររបស់
លោកយ៉ូសែបដែលនៅស្រុកឆ្ងាយផង។



មានមនុស្សជាច្រើនពីប្រទេសផ្សេងៗ បានធ្វើដំណើរមកទិញស្បៀង
អាហារនៅស្រុកអេស៊ីប។ លោកយ៉ាកុបមានប្រសាសន៍ទៅកាន់កូនៗ
របស់លោកថា ៖ “ចូរកូននាំគ្នាទៅរកទិញស្បៀងអាហារ
នៅស្រុកអេស៊ីប
ដើម្បីកុំឲ្យ
យើងស្លាប់ដោយ
ការអត់ឃ្លានសោះ
ឡើយ”។



កូនៗរបស់លោកយ៉ាកុបក៏បានទៅដល់ស្រុកអេស៊ីប
ដើម្បីរៀបចំទិញស្បៀងអាហារ។



កូនៗ របស់លោកយ៉ាកុប បានលុតជង្គង់ក្រាបក្បាល
ដល់ដីនៅចំពោះមុខព្រះអម្ចាស់ដែលមាននាទីគ្រប់គ្រង
ស្រុកអេស៊ីប។ ពួកគេមើលលោកយ៉ូសែបដែលត្រូវជាប្អូន
មិនស្គាល់ទេ។ ប៉ុន្តែលោកយ៉ូសែប ស្គាល់ពួកគេច្បាស់
ណាស់។ លោកយ៉ូសែប បាននឹកឃើញសុបិន្តដែល
លោកបានសុបិន្តឃើញតាំងពីក្មេងនោះ។ ព្រះជាអម្ចាស់
បានលើកលោកឡើងឲ្យខ្ពស់ជាងបងៗ របស់លោក។



លោកយ៉ូសែប ជាមនុស្សឆ្លាត។
លោកមានប្រសាសន៍ទៅកាន់បងៗ យ៉ាងតឹងរ៉ឹង
ហើយឲ្យគេទុកលោកស៊ីម្មានជាថ្នរ។
បន្ទាប់មកលោកបង្គាប់គេថា ៖



“អ្នកផ្សេងទៀត ត្រូវវិលត្រឡប់ទៅស្រុកវិញ
ដោយយកស្បៀងអាហារទៅឲ្យក្រុមគ្រួសារ
ដែលកំពុងតែអត់ឃ្លាននោះចុះ បន្ទាប់មក
ត្រូវនាំប្អូនរបស់ឯងរាល់គ្នាមកជួបខ្ញុំ
ទើបខ្ញុំជឿថា ពួកលោកមិនមែនជាអ្នក
ស៊ើបការណ៍ទេ”។



បងៗ របស់លោកយ៉ូសែប យល់ថា គឺព្រះជាម្ចាស់
កំពុងដាក់ទោសពួកគេ ដោយព្រោះតែការលក់
លោកយ៉ូសែបឲ្យធ្វើជាទាសករ
កាលពីជាច្រើនឆ្នាំមុន។



លោកយ៉ាកុប និង កូនៗ របស់លោក មានចិត្តភ័យយ៉ាងខ្លាំង។ ពេល
ចាក់ស្រូវចេញពីបាវ ម្នាក់ៗបានឃើញថង់ ប្រាក់រៀងៗខ្លួន។ ពួកគេ
និយាយគ្នាថា ៖ “គេបានដាក់ថង់ប្រាក់របស់យើង
នៅក្នុងបាវស្រូវរបស់យើងវិញ ហើយលោក
ដែលជាអ្នកគ្រប់ គ្រងស្រុកនោះបានបង្គាប់
យើងយ៉ាងម៉ឺងម៉ាត់ថា ឲ្យនាំយកបេនយ៉ា
មីនទៅជាមួយ”។



លោកយ៉ាកុប នឹងមិនឲ្យបេនយ៉ា មីនទៅនោះទេ។ ប៉ុន្តែ
ពេលលោកជិតអស់ស្បៀងអាហារប្រើប្រាស់ហើយនោះ។
បងៗរបស់លោកត្រូវតែវិលទៅស្រុកអេស៊ីប វិញ
ដោយយកបេនយ៉ាមីនទៅជាមួយផង។



កាលលោកយ៉ូសែបបានឃើញបេនយ៉ាមីន លោកបានបញ្ជាឲ្យអ្នកបម្រើរបស់លោកបានរៀបចំពិធីជប់លៀងយ៉ាងធំ។ គេបានអញ្ជើញបងៗទាំងអស់របស់លោកឲ្យចូលរួមក្នុងពិធីជប់លៀងនោះ។ លោកយ៉ូសែបសួរថា ៖ “ពីមុន អ្នករាល់គ្នាប្រាប់ខ្ញុំថាមានឪពុកចាស់ហើយ តើគាត់សុខសប្បាយជាទេ? គាត់នៅរស់ទេឬ?”។ ប្រហែលជាលោកយ៉ូសែប បានកំពុងគិតអំពីរបៀប ដែលលោកនឹងនាំគ្រួសារទាំងមូលមករស់នៅជាមួយគ្នាហើយមើលទៅ។



លោកយ៉ូសែប ក៏ចង់ដឹងដែរថា
តើបងៗរបស់លោកពិតជាស្តាយកំហុសដែល
ពួកគេបានប្រព្រឹត្តកាលប៉ុន្មានឆ្នាំមុនឬទេ។



ក្រោយពីជប់លៀងចប់ លោកក៏បានចោទប្រកាន់ពួកគេពីបទលួច។ លោកយ៉ូសែបមានប្រសាសន៍ថា ៖ “ដើម្បីដាក់ទោសអ្នក រាល់គ្នា ខ្ញុំត្រូវតែយកបេនយ៉ាមីនធ្វើជាទាសកររបស់ខ្ញុំ”។
លោកយ៉ូដាបានសុំអង្វរថា ៖ “សូមលោកម្ចាស់ យកជីវិតខ្ញុំជំនួសប្អូនខ្ញុំវិញចុះ”។



លោកយ៉ូសែប បានដឹងថា លោកយូដា ជាអ្នកដែលបានផ្តល់យោបល់ឲ្យលក់លោកជាទាសករនោះ ពេលនេះបានផ្លាស់ប្តូរយ៉ាងពិតប្រាកដហើយ។

ដោយទប់ចិត្តលាក់សេចក្ដីស្រឡាញ់ចំពោះ
គ្រួសារលោកមិនបាននោះ លោកយ៉ូសែបក៏បាន
បញ្ជារឲ្យជនជាតិអេស៊ីប ទាំងអស់
ចេញពីបន្ទប់នោះ។





បន្ទាប់មកលោកចាប់ផ្ដើមយំយ៉ាងខ្លាំង ហើយ
មានប្រសាសន៍ថា ៖ “ខ្ញុំនេះហើយជាយ៉ូសែប
ដែលបងៗ បានលក់មកស្រុកអេស៊ីបនេះ”។

ពួកបងៗរបស់លោក
យ៉ូសែប ងឿងឆ្ងល់
ហើយភ័យខ្លាច និង
រកពាក្យនិយាយ
មិនបាន។



លោកយ៉ូសែប លើកទឹកចិត្តបងៗ ហើយមានប្រសាសន៍ថា
៖ ព្រះជាម្ចាស់បានលើកខ្ញុំឡើងឲ្យ
ធ្វើជាព្រះ

អម្ចាស់នៃស្រុក អេស៊ីប
ដើម្បីឲ្យខ្ញុំអាចសង្គ្រោះជីវិត
បងៗឲ្យរួចពីទុរ្ភិក្សនេះ។ ចូរវិលទៅ
ស្រុកវិញ ហើយនាំលោកឪពុក
របស់ខ្ញុំមកទីនេះ។ ខ្ញុំនឹង មើល
ខុសត្រូវថែរក្សាបងៗទាំងអស់គ្នា។

លោកយ៉ាកុប និង លោកយ៉ូសែប
បានជួបជុំគ្នានៅស្រុកអេស៊ីប

ហើយក្រុមគ្រួសារ
ទាំងមូលក៏បានរស់នៅទីនោះ
យ៉ាងសុខសាន្ត និង
ចម្រុងចម្រើន។



ព្រះជាម្ចាស់លើកកិត្តយលោកយ៉ូសែបដែលជាទាសករ

រឿងមួយពីព្រះបន្ទូលរបស់ព្រះជាម្ចាស់,

អាចរកឃើញនៅក្នុងព្រះគម្ពីរ

លោកុប្បត្តិ ៣៩-៤៥

“ការស្វែងយល់ព្រះបន្ទូលរបស់ព្រះអង្គ ធ្វើឲ្យមនុស្សភ្លឺស្វាង
ហើយធ្វើឲ្យអ្នកទន់ទាបមានប្រាជ្ញា។”
ទំនុកតម្កើង 119:130

ចប់

រឿងព្រះគម្ពីរនេះប្រាប់យើងពីព្រះជាម្ចាស់ដ៏អស្ចារ្យរបស់យើងដែលបានបង្កើតយើងមក ហើយចង់អោយអ្នកស្គាល់ទ្រង់។

ព្រះអង្គជ្រាបថា យើងបានប្រព្រឹត្តអំពើអាក្រក់, ដែលទ្រង់ហៅការទាំងនោះថាជា អំពើបាប។ ទោសនៃអំពើបាបគឺសេចក្តីស្លាប់, ប៉ុន្តែព្រះទ្រង់ស្រឡាញ់យើងខ្លាំងណាស់ ដល់ម្ល៉េះហើយបានជាទ្រង់បានចាត់ព្រះយេស៊ូដែលជាព្រះរាជបុត្រាតែមួយរបស់ព្រះអង្គអោយមកសុគតនៅលើឈើឆ្កាង ហើយបង់ថ្លៃនៃទោសនោះជំនួសយើង។ ព្រះយេស៊ូបានរស់ពីសុគតឡើងវិញ ហើយបានយាងត្រលប់ទៅស្ថានសួគ៌! ប្រសិនបើអ្នកជឿលើព្រះយេស៊ូ ហើយសុំទ្រង់អោយអភ័យទោសចំពោះអំពើបាបរបស់អ្នក, ទ្រង់នឹងលើកលែងទោសអោយអ្នក! ទ្រង់នឹងមក ហើយរស់ក្នុងចិត្តរបស់អ្នកឥឡូវនេះ, ហើយអ្នកនឹងរស់នៅជាមួយទ្រង់ជារៀងរហូត។

ប្រសិនបើអ្នកជឿថានេះជាការពិត, អ្នកត្រូវទូលទៅកាន់ព្រះអង្គថា៖ ឱព្រះយេស៊ូទូលបង្គំជឿហើយថាទ្រង់ជាព្រះ ហើយបានក្លាយជាមនុស្សម្នាក់មកដើម្បីសុគតជំនួសអំពើបាបរបស់ទូលបង្គំ, ហើយពេលនេះទ្រង់រស់ពីសុគតឡើងវិញ។ សូមទ្រង់យាងចូលក្នុងជីវិតរបស់ទូលបង្គំ ហើយអភ័យទោសចំពោះអំពើបាបរបស់ទូលបង្គំ ដើម្បីទូលបង្គំអាចមានជីវិតថ្មីនាពេលឥឡូវនេះបាន ហើយថ្ងៃមួយទូលបង្គំនឹងទៅនៅជាមួយទ្រង់ជារៀងរហូត។ សូមជួយទូលបង្គំអោយគោរពទ្រង់ហើយរស់នៅសំរាប់ទ្រង់ដូចជាបុត្ររបស់ទ្រង់។ អាម៉ែន។

សូមអានព្រះគម្ពីរ ហើយអធិដ្ឋានទៅព្រះជារៀងរាល់ថ្ងៃ! យ៉ូហាន ៣:១៦